# ទំនាក់ទំនងសំខាន់ៗ

FEMA
(800) 621-FEMA (3362)
(800) 462-7585 (TTY)
www.fema.gov

ទូរស័ព្ទជំនួយគ្រោះមហន្តរាយ SBA
(800) 659-2955

ការពិគ្រោះយោបល់អំពីវិបត្តិ
(800) 273-8255 ឬ
(866) 615-8700

កាកបាទក្រហមអាមេរិក
(800) 975-7585

សន្តិសុខសង្គម
(800) 772-1213
(800) 325-0778 (TTY)

ទ័ពសង្គ្រោះ
(800) 725-2769

សេវាកម្មច្បាប់គ្រោះមហន្តរាយ
(800) 310-7029

ក្រសួងសេវាកម្មសង្គម
លេខទូរស័ព្ទជំនួយគ្រោះមហន្តរាយ
(888) 524-3578

សេវាប្រៃសនិយសហរដ្ឋអាមេរិក
(800) 275-8777

ស្វែងរកគ្រួសារជាតិ
លេខទូរស័ព្ទកណ្តាល
(866) 326-9393



# ជំរករថយន្តសណ្តោង និង ផ្ទះចល័ត

## ផ្ទះរបស់អ្នក នៅឆ្ងាយពីផ្ទះដើម បន្ទាប់ពីគ្រោះមហន្តរាយ

ធ្វើអោយការស្នាក់នៅរបស់អ្នកមានសុវត្ថិភាព នៅក្នុងជំរកគ្រោះមហន្តរាយបណ្តោះអាសន្ន ដែល ផ្តល់ដោយភ្នាក់ងារគ្រប់គ្រងគ្រាអាសន្នរបស់សហព័ន្ធ **(FEMA)** និង រដ្ឋលូស៊ីអាណា អានពីរបៀបៈ

- ថែរក្សាផ្ទះបណ្តោះអាសន្នរបស់អ្នក
- ប្រុងប្រយ័ត្នពីអគ្គីភ័យ និង សុវត្ថិភាព
- ចៀសវាងការបន្លំ និង លក់យកប្រាក់
- ត្រៀមខ្លួនសំរាប់គ្រាអាសន្ន
- កំណត់តំរូវការបន្តរបស់អ្នកសំរាប់ជំរកបណ្តោះអាសន្ន



រថយន្តសណ្តោង ឬ ផ្ទះចល័ត ដែលអ្នកនឹងរស់នៅក្នុង គឺជាជំរកបណ្តោះអាសន្ន ប៉ុន្តែ អ្នកអាចធ្វើអោយវាក្លាយជាផ្ទះឆ្ងាយពីផ្ទះដើមរបស់អ្នក ។ វាផ្តល់នូវភាពជាឯកជន និង ឱកាស ដើម្បីត្រលប់ទៅកាន់ជីវិតរបស់អ្នកវិញ បន្ទាប់ពីគ្រោះមហន្តរាយ ។ ទំព័រទាំងនេះ ផ្តល់ព័ត៌មានអំពីអ្វីដែលត្រូវធ្វើ មុនពេលផ្លាស់ចូលទៅកាន់រថយន្តសណ្តោង ឬ ផ្ទះចល័តនេះ របៀបធ្វើអោយគ្រួសាររបស់អ្នកមានសុវត្ថិភាព និង របៀបរក្សាជំរកនេះ ។

មុនពេលចុះហត្ថលេខាទទួលយករថយន្តសណ្តោង ឬ ផ្ទះចល័តរបស់អ្នក ធានាថាអ្វីៗមានដំណើរការស្ថិតក្នុងលក្ខខណ្ឌល្អប្រសើរ ហើយ អ្នកត្រួតពិនិត្យបានបញ្ជាក់ថា "រួចរាល់សំរាប់ការកាន់កាប់" (RFO) ។

## ថែទាំផ្ទះបណ្តោះអាសន្នរបស់អ្នក ..... ពាក្យពេចន៍អំពីច្បាប់ និង ការទទួលខុសត្រូវនានា

អ្នកមានការទទួលខុសត្រូវដោយអន្លើ សំរាប់ការថែទាំផ្ទះបណ្តោះអាសន្ននេះ ។ រក្សាវាអោយបានស្អាត និង មានរបៀបរៀបរយ ។ មានរបស់របរជាច្រើន ដែលអ្នកអាចថែទាំដោយខ្លួនអ្នកបានដោយងាយស្រួល និង ដោយសុវត្ថិភាព ដោយពុំបាច់ទូរស័ព្ទសុំជំនួយវិជ្ជាជីវៈ ។ នេះគឺជាអ្វី ដែលអ្នក ត្រូវធ្វើសំរាប់ការថែទាំងាយៗ:

- ផ្លាស់ប្តូរអំពូលភ្លើង និង ឧបករណ៍ប្រើផ្ទះតូចៗ ដូចជា ឧបករណ៍ចាប់ផ្សែងជាដើម ។
- ធានាថាឧបករណ៍ប្រើប្រាស់ត្រូវបានភ្ជាប់ទៅនឹងចរន្តអគ្គិសនី ។ កុំប្រើខ្សែភ្លើងអគ្គិសនីលើសចំណុះ ដោយប្រើប្រាស់ឧបករណ៍អគ្គិសនីលើសពីពីរ ក្នុងពេលជាមួយគ្នា ។
- ពិនិត្យមើលខ្នាតវង្វាស់ធុងហ្គាស ។ រាយការណ៍ពីការលេចធុងហ្គាសភ្លាម ។
- បំពេញធុងហ្គាសឡើងវិញ ។
- ចេញថ្លៃប្រើប្រាស់ទឹកភ្លើងរបស់អ្នក (នៅក្នុងករណីភាគច្រើន) ។

### ក្រសួងសន្តិសុខដែនដីសហរដ្ឋអាមេរិក
### អង្គភាពគ្រប់គ្រងគ្រោះអាសន្នរបស់សហព័ន្ធ
### ជំរកគ្រោះអាសន្ន ~ កិច្ចព្រមព្រៀងចំពោះវិធាននៃការកាន់កាប់

| FEMA DR# | ទីតាំង # | កន្លែង # |
|---|---|---|
| | | |

ខ្ញុំទទួលស្គាល់ និង យល់ថា FEMA ផ្តល់ជំរកនេះមកអោយខ្ញុំ ជាជំរកបណ្តោះអាសន្ន ព្រោះលោកប្រធានាធិបតីបានប្រកាសពីគ្រោះមហន្តរាយ ឬ គ្រោះអាសន្ននៅក្នុងតំបន់ ហើយ ខ្ញុំមិនអាចរស់នៅក្នុងផ្ទះរបស់ខ្ញុំបាន ដោយសារតែព្រឹត្តិការណ៍នេះ ។ ខ្ញុំយល់ថា នេះគឺជាជំរកបណ្តោះអាសន្ន ហើយ ថាខ្ញុំអាចត្រូវបានតំរូវអោយផ្លាស់ប្តូរទីតាំង ប្រសិនបើបញ្ហាមួយក្នុងចំណោមបញ្ហាខាងក្រោមនេះកើតមានឡើង នៅពេលដែល ជំរើសទីជំរកកើតមានឡើង ប្រសិនបើ FEMA សំរេចថាខ្ញុំពុំមានសិទ្ធិស្របច្បាប់ សំរាប់ទីជំរកនេះ ឬ នៅពេលដែល បញ្ឈប់ប្រតិបត្តិការផ្តល់ទីជំរក ។ សូមមើល 42 U.S.C. 5170B ។

ខ្ញុំត្រូវបានជូនដំណឹង និង យល់ថា ការប្រព្រឹត្តល្មើសនឹងវិធាណាមួយដែលមានខាងក្រោមនេះ អាចតំរូវអោយខ្ញុំត្រូវចាកចេញពីទីជំរកនេះភ្លាម ។ ខ្ញុំព្រមព្រៀងថា:

(1) ត្រូវថែទាំជំរកនេះ និង ទីកន្លែងជុំវិញអោយបានស្អាត

(2) មិនប្រព្រឹត្តបទឧក្រិដ្ឋ ឬ អនុញ្ញាតអោយមានបទឧក្រិដ្ឋ កើតឡើងនៅក្នុងជំរកនេះ ឬ បរិវេណជុំវិញ

(3) មិនអនុញ្ញាតអោយនរណាម្នាក់ ក្រៅពីបុគ្គលដែលបានរៀបរាប់ខាងក្រោមនេះ រស់នៅក្នុងជំរកនេះ

(4) ត្រូវទទួលយកជំរើសជំរកផ្សេងទៀត នៅពេលដែលមានជំរើសទាំងនោះ

(5) ត្រូវកាន់កាប់ជំរកនេះជាបន្ត ហើយ ត្រូវស្វែងរកការឯកភាពពី FEMA ប្រសិនបើចាកចេញពីជំរកនេះសំរាប់រយៈពេលវែងមួយ

(6) ត្រូវគោរពសិទ្ធិ និង ភាពជាឯកជន របស់បុគ្គលផ្សេងទៀតនៅក្នុងសួនច្បារ ដូចដែលបានបញ្ជាក់នៅក្នុងវិធានរបស់សួនច្បារ ដែលមានភ្ជាប់មកជាមួយ

(7) មិនត្រូវផ្លាស់ប្តូរទីតាំងរបស់ជំរកនេះ ទៅកន្លែងផ្សេងទៀត

| ឈ្មោះមនុស្សដែលទទួលជំរកនេះ (សូមព្រីន) | ហត្ថលេខាមនុស្សដែលទទួលជំរកនេះ | កាលបរិច្ឆេទ |
|---|---|---|
| | | |

*(ត្រូវបំពេញដោយអ្នកដែលទទួលជំរកនេះ)*

សមាជិកគ្រួសារ - ព័ត៌មានអ្នកកាន់កាប់

| ឈ្មោះ | អាយុ | ភេទ |
|---|---|---|
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |
| | | |

| Site Control # | Unit Bar Code # | Unit Vin # |
|---|---|---|
| | | |

| ឈ្មោះមនុស្សដែលប្រគល់ជំរកនេះ (សូមព្រីន) | ហត្ថលេខាមនុស្សដែលប្រគល់ជំរកនេះ | កាលបរិច្ឆេទ |
|---|---|---|
| | | |

## វ៉ិបសាយលូស៊ីអាណាសំខាន់ៗ

| | |
|---|---|
| ទីក្រុងញូវអរលីន | www.cityofno.com |
| ទីក្រុងឡេកឆាល | www.cityoflakecharles.com |
| ការិយាល័យអភិបាល | www.gov.louisiana.gov |
| វ៉ិបសាយហ្វ៊ីរីគែនកាទ្រីណា | www.katrina.louisiana.gov |
| ក្រសួងកសិកម្ម និង រុក្ខាប្រម៉ាញ់ | www.ldaf.louisiana.gov |
| ក្រសួងវប្បធម៌ ការលំហែ និង ទេសចរណ៍ | www.crt.louisiana.gov |
| ក្រសួងសុខាភិបាល និង មន្ទីរពេទ្យ | www.dhh.louisiana.gov |
| ក្រសួងចំណូល | www.revenue.louisiana.gov |
| ក្រសួងធនធានធម្មជាតិ | www.dnr.louisiana.gov |
| ក្រសួងសេវាសង្គម | www.dss.louisiana.gov |
| ក្រសួងដឹកជញ្ជូន និង អភិវឌ្ឍន៍ | www.dotd.louisiana.gov |
| ក្រសួងរតនាគារ | www.treasury.louisiana.gov |
| ក្រសួងសត្វព្រៃ និង នេសាទ | www.wlf.louisiaana.gov |
| សន្តិសុខមហាផ្ទៃ និង ការត្រៀមគ្រាអាសន្ន | www.ohsep.louisiaina.gov |
| ការិយាល័យអគ្គមេធាវី | www.ag.state.la.us |
| ការិយាល័យរដ្ឋលេខាធិការ | www.sos.louisiana.gov |
| ការិយាល័យអភិវឌ្ឍន៍យុវជន | www.oyd.louisiana.gov |
| ផ្នែករដ្ឋបាល | www.doa.louisiana.gov |
| ក្រសួងកែលំអ | www.doc.louisiana.gov |
| ក្រសួងមុខងារសាធារណៈ | www.dscs.louisiana.gov |
| ក្រសួងអប់រំ | www.doe.louisiana.gov |
| ក្រសួងសុវត្ថិភាពសាធារណៈ | www.dps.louisiana.gov |

ប្រសិនបើមានរបស់របរខូចខាត ដោយសារការប្រើប្រាស់មិនប្រក្រតី FEMA នឹងចេញវិក្កយប័ត្រអោយអ្នកសំរាប់ការជួសជុល ។

កុំភ្ជាប់រនាំងបាំងសាច រានហាល ឬ ធ្វើការផ្លាស់ប្តូរដទៃទៀត ចំពោះជំរកបណ្តោះអាសន្នរបស់អ្នក ។

មានប្រអប់កុងសង់ទ័រភ្លើងពីរ មួយនៅខាងក្នុង និង មួយទៀតនៅលើបង្គោលភ្លើងខាងក្រៅ ឬ នៅឯផ្ទះខូចខាត ។

ម្តងម្កាល មាន**បញ្ហា** កើតឡើង ... តើវាជាបញ្ហាមួយក្នុងចំណោមបញ្ហា ទាំងនេះឬ?

- **សុខភាព ឬ សុវត្ថិភាព**របស់អ្នកស្ថិតនៅក្នុងគ្រោះថ្នាក់ ។ ចាកចេញពីជំរកបណ្តោះអាសន្ន ទាក់ទងអាជ្ញាធរពាក់ព័ន្ធ ដូចជាមន្ទីរអគ្គីភ័យ មន្ទីរប៉ូលីស ឬ មន្ទីរពិនិត្យជាតិពុល ។ ទាក់ទង FEMA ប្រសិនបើគ្រោះថ្នាក់ទាក់ទងនឹងរថយន្តសណ្តោង ឬ ផ្ទះចល័ត ។
- ត្រូវ**ថែរក្សា ឬ ជួសជុល** ។ មានកិច្ចការជាច្រើន ដែលអ្នកអាចធ្វើដោយខ្លួនអ្នក ។
- **ការជួសជុលពិបាកៗ ឬ មានគ្រោះថ្នាក់** ។ ទូរស័ពហៅក្រុមជួសជុលរបស់ FEMA ។ បញ្ជីនៅខាងក្រោយកូនសៀវភៅនេះ មានលេខទូរស័ព្ទរបស់ការិយាល័យជួសជុល ។ សូមទូរស័ព្ទទៅកាន់ការិយាល័យ នៅក្នុងតំបន់ដែលអ្នករស់នៅ ។

### កំណត់សំគាល់សំខាន់

អ្នករស់នៅក្នុងរថយន្តសណ្តោង និង ផ្ទះចល័តរបស់ FEMA ដែលរួមទាំងរថយន្តសណ្តោង និង ផ្ទះចល័តជាលក្ខណៈឯកជន ត្រូវចុះហត្ថលេខាលើកិច្ចព្រមព្រៀងកាន់កាប់ និង ក្រដាសបំពេញវិធាន និង បទបញ្ជានានា ។ ឯកសារទាំងនេះ មាននៅចុងបញ្ចប់របស់កូនសៀវភៅនេះ សំរាប់ការយោងនាពេលអនាគត ។

**អ្នករស់នៅត្រូវបានក្រើនរំលឹកផងដែរ ថាពួកគេមិនត្រូវបានអនុញ្ញាតអោយផ្លាស់ប្តូរទីតាំងរថយន្តសណ្តោងពីកន្លែងមួយទៅកន្លែងមួយទៀតឡើយ ។**

ប្រសិនបើមាននរណាម្នាក់នៅក្នុងរថយន្តសណ្តោង ឬ ផ្ទះចល័តរបស់ FEMA បំពានវិធាននេះ គ្រួសារទាំងមូលអាចត្រូវបានបណ្តេញចេញ ។

## ការប្រុងប្រយ័ត្នសុវត្ថិភាព
## អគ្គីភ័យ ព្យុះថូណាដូ និង ហ្វើរីកែន



### កណ្តឹងផ្សែងអោយសញ្ញាសង្គ្រោះជីវិតមនុស្ស

ផ្នែកទីមួយនៃផែនការសុវត្ថិភាពសំរាប់គ្រប់ផ្ទះទាំងអស់ គឺត្រូវផ្តល់ការព្រមានដល់អ្នករស់នៅក្នុងផ្ទះលឿនជាមុន។

វិធីដែលល្អបំផុត ដើម្បីទទួលបានការព្រមានលឿនបំផុតពីគ្រោះថ្នាក់អគ្គីភ័យ គឺដោយការតំលើងកណ្តឹងផ្សែងផ្សែង។ ផ្ទះនានាគួរមានកណ្តឹងផ្សែងនៅជិតបន្ទប់គេង និង នៅជិតចង្ក្រានបាយ។

រថយន្តសណ្តោង ឬ ផ្ទះចល័យ របស់អ្នកមានបំពាក់កណ្តឹងផ្សែងប្រើថ្ម។ តេស្តសាកល្បងវាម្តងក្នុងមួយខែ ហើយ ជំនួសថ្មពេលដែលចាំបាច់។

ផ្តោតការប្រុងប្រយ័ត្នចំពោះការព្រមានថូណាដូសហគមន៍ភ្លាម។

### ធ្វើផែនការភាររត់គេចរបស់អ្នក

ផ្នែកទី 2 នៃផែនការសុវត្ថិភាពអគ្គីភ័យ ឬ ថូណាដូ គឺគ្រប់រូបត្រូវមានសុវត្ថិភាពអោយបានលឿន។ អគ្គីភ័យនៅក្នុងផ្ទះ អាចជាឃាតករនៅក្នុងពេលតែ 3 នាទី។ ជារើយៗ ថូណាដូផ្តល់ការព្រមានជាមុនតិចតួច។

- ហាត់ហ្វឹកហ្វឺនផែនការរត់គេចរបស់អ្នកមុនពេល ដូច្នេះអ្នកអាចធ្វើចលនាបានលឿន សូម្បីតែនៅពេលអ្នកភ្ញាក់នៅកណ្តាលអធ្រាត ហើយ ធានាថាកូនរបស់អ្នកដឹងពីផែនការរត់គេចនេះ។
- ធានាថាគ្រប់គ្នា ដឹងពីទីកន្លែងទ្វារចេញ ដូច្នេះ ពុំមានការខាតពេលវេលា នៅពេលដែលមានគ្រោះមហន្តរាយកើតឡើង។
- ហាត់វារនៅក្រោមផ្សែង។
- ត្រៀមទីកន្លែងមុនពេលរៀបចំការជួបជុំមួយ នៅខាងក្រៅផ្ទះរបស់អ្នក។
- សំរាប់អគ្គីភ័យ **សូមទូរស័ព្ទទៅលេខ 911** ពីទូរស័ព្ទដៃ ឬ ពីទូរស័ព្ទអ្នកជិតខាង។ ពេលនៅខាងក្រៅផ្ទះ សូមនៅខាងក្រៅផ្ទះ។

## ទូរស័ព្ទបន្ទាន់ថែទាំរថយន្តសណ្តោង

ប្រសិនបើអ្នករស់នៅក្នុងតំបន់ខាងក្រោម ហើយ ត្រូវការជួសជុលថែទាំ
សូមទូរស័ព្ទទៅ Shaw តាមលេខ:

**1-866-903-7429**

East Baton Rouge
Jefferson
Ouachita

Orleans (downtown) ក្នុងហ្ស៊ីបកូដខាងក្រោម:

| | |
|---|---|
| 70112 | 70119 |
| 70113 | 70122 |
| 70115 | 70124 |
| 70116 | 70125 |
| 70117 | 70130 |
| 70118 | |

Lincoln
West Baton Rouge

ប្រសិនបើអ្នករស់នៅក្នុងតំបន់ខាងក្រោម ហើយ ត្រូវការជួសជុលថែទាំ
សូមទូរស័ព្ទទៅ CH2MHill តាមលេខ:

**1-800-774-3249**

Lafourche
St. Charles

Orleans (ជិត St. Bernard)
ក្នុងហ្ស៊ីបកូដខាងក្រោម:

70114
70117
70131

Terrebonne

# ទូរស័ព្ទបន្ទាន់ថែទាំរថយន្តសណ្តោង

ប្រសិនបើអ្នករស់នៅក្នុងតំបន់ខាងក្រោម ហើយ ត្រូវការជួសជុលថែទាំ
សូមទូរស័ព្ទទៅ Fluor តាមលេខ:

1-866-360-6432

| | | |
|---|---|---|
| Acadia | Jackson | Pointe Coupee |
| Allen | Jefferson Davis | Rapides |
| Ascension | La Salle | Red River |
| Assumption | Lafayette | Richland |
| Avoyelles | Livingston | Sabine |
| Beauregard | Madison | St. Bernard |
| Bienville | Morehouse | St. Helena |
| Bossier | Natchitoches | St. James |
| Caddo | | St. John the Baptist |
| Calcasieu | Orleans (N of I-10) | St. Landry |
| Caldwell | ក្នុងហ្សិបកូដខាងក្រោម: | St. Martin |
| Cameron | | St. Mary |
| Catahoula | | St. Tammany |
| Claiborne | | Tangipahoa |
| Concordia | 70122 | Tensas |
| DeStoto | 70124 | Union |
| East Carrol | 70126 | Vermillion |
| East Feliciana | 70127 | Vernon |
| Evangeline | 70128 | Washington |
| Franklin | 70129 | Webster |
| Grant | | West Carroll |
| Iberia | | West Feliciana |
| Iberville | | Winn |

## ដំបូន្មានសុវត្ថិភាពអគ្គីភ័យ

**សូមធ្វើតាមការប្រុងប្រយ័ត្នខាងក្រោម នៅពេលរស់នៅក្នុងរថយន្តសណ្តោង ឬ ផ្ទះចល័ត ដើម្បីជួយធានាអោយមានបរិស្ថានសុវត្ថិភាព និង គ្មានអគ្គីភ័យ**

- ប្រើការបំភ្លឺអគ្គិសនី ឬ ថ្ម នៅក្នុងរថយន្តសណ្តោង។ កុំប្រើភ្លើងទៀន ឬ ចង្កៀងសំរាប់បំភ្លឺ ផ្តល់កំដៅ ឬ ចំអិនម្ហូប ហើយ ទុកដាក់គ្រប់ឧបករណ៍ចំអិនអាហារ និង ផ្តល់កំដៅទាំងអស់ នៅក្នុងលក្ខខណ្ឌល្អប្រសើរ។
- កុំប្រើជន្ទៀសធ្យូង ឬ ហ្គាស នៅខាងក្នុង ហើយ កុំប្រើឧបករណ៍កំដៅប្រើប្រេងកាតនៅខាងក្នុងរថយន្តសណ្តោង។ ផ្សែងពុល
- បង្កគ្រោះថ្នាក់ ដល់សុខភាពអ្នក។
- ប្រើតែឧបករណ៍ចំអិនម្ហូប ដែលបានតំលើងនៅក្នុងរថយន្តសណ្តោង។
- ទុកដាក់របស់របរងាយឆេះ ដូចជា ក្រដាស ក្រណាត់ និង ថ្នាំងនានា អោយនៅឆ្ងាយពីឧបករណ៍ចំអិនម្ហូប និង ផ្តល់កំដៅ ហើយ បិទឧបករណ៍ទាំងអស់នោះ មុនពេលចាកចេញ។
- មុនពេលចូលគេង ពន្លត់ឧបករណ៍មានផ្សែងទាំងអស់ ហើយ ជ្រលក់វាជាមួយទឹក។ កុំជក់បារីនៅលើគ្រែ!
- ដឹងពីទីកន្លែងទុកបំពង់ពន្លត់អគ្គីភ័យ នៅក្នុងរថយន្តសណ្តោង ហើយ រៀនប្រើប្រាស់វា។ ចងចាំថាត្រូវទុកវានៅជិតច្រកចេញ។ ធានាថារន្ធខ្យល់ផ្សែងកំដៅនៅផ្នែកខាងក្រៅរថយន្តសណ្តោង មិនត្រូវបានបិទ ឬ គ្រប។

## ដំបូន្មានសុវត្ថិភាពហ្ស៊ីរ៉ែគែន

នៅពេលដែលមានការអោយប្រុងប្រយ័ត្ន ឬ ការព្រមានពីហ្ស៊ីរ៉ែគែន:

- គ្មានរថយន្តសណ្តោង ឬ ផ្ទះចល័តណា - មិនថាវាថ្មីប៉ុណ្ណានោះទេ - អាចជាជំរកសុវត្ថិភាពពីព្យុះត្រូពិច ឬ កំលាំងខ្យល់បក់ខ្លាំងហ្ស៊ីរ៉ែគែនបានទេ។
- ពុំមានសេចក្តីណែនាំបច្ចេកទេសបោះពុម្ពផ្សាយ ពីរបៀបដែលរថយន្តសណ្តោងអាចដំណើរការបានល្អ នៅក្នុងស្ថានភាពមានខ្យល់បក់ខ្លាំងឡើយ។
- អ្នករស់នៅក្នុងរថយន្តសណ្តោង ឬ ផ្ទះចល័ត ដែលផ្តល់ដោយ FEMA គួរផ្លាស់ប្តូរទីតាំង ទៅកាន់អាគារនៅជិត ដែលមានសុវត្ថិភាពជាង នៅពេលដែលអាជ្ញាធរមូលដ្ឋាន ចេញការព្រមានពីហ្ស៊ីរ៉ែគែនសំរាប់សហគមន៍របស់ពួកគេ។
- ធានាសុវត្ថិភាព ឬ នាំចូលក្នុងនូវគ្រប់របស់របរ ដែលអាចហើរតាមខ្យល់បក់ខ្លាំងបាន។
- តាមដានការផ្លាស់ប្តូរលក្ខខណ្ឌ នៅពេលដែលអ្នកមើលទូរទស្សន៍ ឬ ស្តាប់វិទ្យុ។
- ចាក់ប្រេងបំពេញរថយន្តរបស់អ្នក។ ពិនិត្យផ្លូវជន្លៀសឡើងវិញ និង ប្រមូលកញ្ចប់របស់របរគ្រាអាសន្នរបស់អ្នក។
- **កុំផ្លាស់ប្តូរទីតាំងរថយន្តសណ្តោង ឬ ផ្ទះចល័តរបស់ FEMA ចេញពីទីតាំងរបស់វា។**

**ប្រសិនបើចាំបាច់ត្រូវមានការជន្លៀស:**

- អ្នក**មិន**គួរផ្លាស់ប្តូរទីតាំងរថយន្តសណ្តោង FEMA របស់អ្នកចេញពីទីតាំងរបស់វា ក្នុងពេលជន្លៀសនោះឡើយ។
- ដរាបណាការបញ្ជាអោយជន្លៀសត្រូវបានប្រកាស បង្កើតផែនការភ្លាម ដើម្បីចាកចេញពីរថយន្តសណ្តោង ឬ ផ្ទះចល័តរបស់អ្នក!
- បិទកុងតាក់ភ្លើងសំខាន់ៗ។
- បិទរ៉ូប៊ីណេទឹកសំខាន់ៗ និង ផ្តាច់ទុយោចេញ។
- បិទធុងហ្គាស។
- យកគ្រឿងដែលងាយរលួយទាំងអស់ចេញពីទូរទឹកកក។
- ប្រមូលគ្រឿងផ្គត់ផ្គង់គ្រាអាសន្នពុំទាន់ដាក់ផ្តុំគ្នា និង សំលៀកបំពាក់ការពារផ្តល់កំដៅ។
- ចៀសវាងផ្លូវមានទឹកជំនន់ និង ប្រយ័ត្នស្ពានដែលទឹកហូរច្រោះអស់។
- មិនថាមនុស្សណាម្នាក់រស់នៅក្នុងរថយន្តសណ្តោង FEMA ឬ របស់ខ្លួនឯងនោះទេ ពួកគេចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់
- ចំពោះសេចក្តីណែនាំក្នុងតំបន់ ដូចជា ជូនដំណឹងដល់អ្នកគ្រប់គ្រងគ្រាអាសន្ន ប្រសិនបើពួកគេត្រូវការជំនួយជាការដឹកជញ្ជូន។

# ការក្លែងបន្លំ និង ការប្រើបំពាន មូលនិធិជំនួយគ្រោះមហន្តរាយ

មនុស្សមួយចំនួនអាចព្យាយាមកេងប្រវ័ញ្ចលើស្ថានភាពនានា ដែលបង្កើតឡើងដោយគ្រោះមហន្តរាយ ។ FEMA និង រដ្ឋ ចង់ធានាអោយបានច្បាស់ថា ជំនួយគ្រោះមហន្តរាយទៅដល់ដៃប្រជាពលរដ្ឋលូស៊ីអាណា ដែលរងគ្រោះដោយហ្យូរីកែនកាទ្រីណា និង រីតា ។ នៅក្នុងការប្រយុទ្ធប្រឆាំងនឹងការក្លែងបន្លំ ការខ្ជះខ្ជាយ និង ការប្រើបំពាន FEMA និង រដ្ឋ លើកទឹកចិត្តប្រជាពលរដ្ឋអោយរាយការណ៍ពីករណីបំពានលើមូលនិធិគ្រោះមហន្តរាយរដ្ឋ និង សហព័ន្ធ ។

**ដើម្បីរាយការណ៍ពីការក្លែងបន្លំ សូមទូរស័ព្ទមកកាន់លេខបន្ទាន់របស់កាទ្រីណា តាមលេខ 1-866-720-5721 ។**

ការិយាល័យអគ្គអធិការរបស់ក្រសួងសន្តិសុខដែនដីរបស់សហរដ្ឋអាមេរិក ធ្វើការស៊ើបអង្កេតលើគ្រប់បណ្តឹងអំពីការក្លែងបន្លំ ការខ្ជះខ្ជាយ និង ការបំពានរបស់គ្រប់ប្រជាពលរដ្ឋទាំងអស់ ដែលពាក់ព័ន្ធជាមួយនឹងមូលនិធិ កម្មវិធីជំនួយ កិច្ចសន្យា ឬ បុគ្គលិក FEMA ។ គ្រប់ព័ត៌មានទាំងអស់នឹងត្រូវរក្សាជាការសំងាត់ ។ អ្នកហៅទូរស័ព្ទពុំចាំបាច់បញ្ចេញឈ្មោះឡើយ ។ អ្នកអាចសរសេរពាក្យបណ្តឹង ហើយ ផ្ញើរទៅកាន់:

**Katrina Fraud Hotline**
**The Pentagon,Washington, D.C. 20301-1900**

## ប្រភេទបណ្តឹងពីការក្លែងបន្លំ ដែលបានប្តឹងទៅកាន់អគ្គអធិការ:

- ប្រើប្រាស់ឈ្មោះក្លែងក្លាយ និង អាសយដ្ឋានច្រើននិង/ឬក្លែងបន្លំ
- ទាមទារការបាត់បង់ដែលពុំមានកើតឡើង ឬ ដែលពួកគេមិនអាចទាមទារបាន
- មិនប្រើប្រាស់មូលនិធិ FEMA សំរាប់គោលបំណងដែលចង់បាន
- មន្ត្រីមូលដ្ឋានប្រើប្រាស់លុយ FEMA ដើម្បីផលប្រយោជន៏ផ្ទាល់ខ្លួន
- មូលប្បទានប័ត្ររបស់ FEMA ត្រូវបានលួច
- ទទួលបានកំរៃពី FEMA និង ក្រុមហ៊ុនធានារ៉ាប់រងរបស់ពួកគេជាន់គ្នា

## នៅពេលអ្នករកបានជំរកអចិន្ត្រៃយ៍:



សូមជូនដំណឹងដល់អ្នកផ្តល់ប្រឹក្សា FEMA របស់អ្នកនៅពេលដែលអ្នកបានរកឃើញជំរកអចិន្ត្រៃយ៍បានហើយ ។ បើអាច អ្នកគួរជូនដំណឹងទៅអោយពួកគេ យ៉ាងហោចណាស់ មួយសប្តាហ៏មុនពេលចាកចេញពីរថយន្តសណ្តោង ឬ ជំរកបណ្តោះអាសន្ន ។ កំណត់ថ្ងៃ និង ពេល ដើម្បីបំពេញការពិនិត្យចាកចេញ ជាមួយអ្នកផ្តល់ប្រឹក្សារបស់អ្នក ។ ចងចាំថាអ្នកនៅតែទទួលខុសត្រូវលើផ្ទះចល័ត ឬ រថយន្តសណ្តោង និង សង្ហារិមរបស់វា រហូតទាល់តែការពិនិត្យចប់សព្វគ្រប់ ហើយ អ្នកបានប្រគល់កូនសោរអោយ វិញ ។

## ទ្រព្យសម្បត្តិចោលនៅក្នុងរថយន្តសណ្តោង ឬ ផ្ទះបណ្តោះអាសន្ន:

ទ្រព្យសម្បត្តិចោលនឹងត្រូវរាប់ចូលជាសន្និធិ យកចេញពីផ្ទះបណ្តោះអាសន្ន និង រក្សាទុក ។ បើអាចអ្នកជួលនឹងត្រូវបានទំនាក់ទំនង ទាក់ទងនឹងទ្រព្យសម្បត្តិផ្ទាល់ខ្លួន ទុកចោលនៅក្នុងផ្ទះបណ្តោះអាសន្ន ហើយ នឹងទទួលបានព័តិមានអំពីដំណើរការនៃការទទួលយកទ្រព្យសម្បត្តិទៅវិញ ។ របស់របរនានា ដែលត្រូវបានរក្សាទុកលើសពី 30 ថ្ងៃ នឹងត្រូវបានបោះចោល ។

## ធនធានសំរាប់ជួលនៅលើអ៊ីនធឺណិត

សំរាប់អ្នកដែលមានអ៊ីនធឺណិតប្រើ ប្រភពព័តិមានអំពីទីជំរក មានលើវ៉ិបសាយ www.dhronline.org. ។ វ៉ិបសាយនេះរៀបរាប់ពីធនធានជំរក ដើម្បីជួយម្ចាស់ដី និង អ្នកជួលសក្តានុពល ស្វែងរកគ្នា ។ គេអាចស្រាវជ្រាវក្នុងវ៉ិបសាយធនធានទីជំរកគ្រោះមហន្តរាយ ដើម្បីស្វែងរកអចលនទ្រព្យតាមតំលៃ ទីតាំង និង ជំរើសជំរក ដូចជាចំនួនបន្ទប់គេ និង បន្ទប់ទឹកជាដើម ។

# លក្ខខណ្ឌកាន់កាប់

## ការបញ្ជាក់សារជាថ្មី និង ការកាន់កាប់ជំរកបណ្តោះអាសន្ន

អ្នកអាចមានសិទ្ធិស្របច្បាប់ ដើម្បីបន្តស្នាក់នៅក្នុងផ្ទះចល័ត ឬ រថយន្តសណ្តោង ផ្អែកទៅលើការបញ្ជាក់សារជាថ្មី ដោយ FEMA ។

ការបញ្ជាក់សារជាថ្មី គឺជាដំណើរការ ដែល FEMA ធ្វើការពិនិត្យឡើងវិញលើផែនការរកជំរកអចិន្ត្រៃយ៍របស់អ្នក ។ ដំណើរការនេះកំណត់ពីសេចក្តីត្រូវការបន្តរបស់អ្នកសំរាប់ជំរកបណ្តោះអាសន្ន ។

បុគ្គលិក FEMA នឹងទាក់ទងអ្នក ដើម្បីពិនិត្យឡើងវិញលើផែនការរបស់អ្នក សំរាប់ការផ្លាស់ប្តូរទៅកាន់ជំរកអចិន្ត្រៃយ៍ ។

បុគ្គលិក FEMA អាចផ្តល់អោយអ្នកនូវព័តិមានធនធានជំរក ដើម្បីជួយអ្នកស្វែងរកទីជំរកដែលមាន ។ បុគ្គលិកទាំងនោះក៏អាចណែនាំអោយស្គាល់អង្គភាពស្ម័គ្រចិត្ត សំរាប់អ្នកដែលមានតំរូវការពិសេស ។



*ដើម្បីបន្តបានសិទ្ធិស្របច្បាប់ស្នាក់នៅក្នុងជំរកបណ្តោះអាសន្នរបស់ FEMA អ្នកត្រូវតែ:*

- *ចាត់វិធានការ ដើម្បីស្វែងរកទីជំរកអចិន្ត្រៃយ៍ នៅកាលបរិច្ឆេទ ដែលឆាប់ជាងគេបំផុត*
- *ទទួលយកទីជំរកដែលមានលក្ខណៈគ្រប់គ្រាន់ នៅពេលដែលអាចរកបាន;*
- *រក្សាទីជំរកបណ្តោះអាសន្ន ដែលត្រូវបានផ្តល់អោយ ក្នុងលក្ខខណ្ឌដូចគ្នានឹងពេលទទួល នៅពេលចូលស្នាក់នៅដំបូង*
- *ធ្វើតាមគ្រប់វិធានទាំងអស់ ដែលបានដាក់ចេញដោយ FEMA លក្ខខណ្ឌនៃកិច្ចព្រមព្រៀងកាន់កាប់ និង ការគ្រប់គ្រងទីជំរក (ទ្រព្យសម្បត្តិពាណិជ្ជកម្ម សួនច្បាររដ្ឋ ឬ ដីឯកជន) ប្រសិនបើរថយន្តសណ្តោង ឬ ផ្ទះចល័តរបស់អ្នក មានទីតាំងនៅក្នុងកន្លែងដែលត្រូវបានគ្រប់គ្រង ។*





## ចៀសវាងការបោកប្រាស់: ពិនិត្យមើលអត្តសញ្ញាណប័ណ្ណ

**ត្រូវប្រុងប្រយ័ត្នចំពោះជនបោកប្រាស់ ដែលក្លែងខ្លួនថាជាបុគ្គលិករបស់ FEMA ឬ អង្គភាពរដ្ឋាភិបាលផ្សេងទៀត ដូចជារដ្ឋបាលអាជីវកម្មធុនតូចរបស់សហរដ្ឋអាមេរិក (SBA) ជាដើម ។ FEMA អ្នកម៉ៅការរបស់ FEMA និង តំណាង SBA នឹងមិនទារលុយសំរាប់សេវាកម្មរបស់ពួកគេឡើយ ។**

វិធីដែលល្អបំផុត ដើម្បីផ្ទៀងផ្ទាត់បុគ្គលិក FEMA ឬ SBA ដែលទទួលបានការអនុញ្ញាត គឺត្រូវ **ពិនិត្យអត្តសញ្ញាណប័ណ្ណមានបិទរូបថតរបស់ពួកគេ** ដែលពួកគេត្រូវពាក់គ្រប់ពេលទាំងអស់ ។

**ចំនុចផ្សេងទៀត ដែលត្រូវចងចាំ:**

- ប្រសិនបើអ្នកជួលអ្នកម៉ៅការអោយធ្វើការសាងសង់ឡើងវិញ ផ្ទៀងផ្ទាត់ជាមួយនឹងការិយាល័យអាជីវកម្មកាន់តែប្រសើរ សមាគមអ្នកសាងសងផ្ទះ ឬ ក្រុមប្រឹក្សាពាណិជ្ជកម្ម ដើម្បីពិនិត្យមើលថាតើក្រុមហ៊ុនម៉ៅការសំណង់ជាប់បណ្តឹងអ្វីដែរឬទេ ។
- មានការសង្ស័យទៅលើនរណាម្នាក់ ដែលចង់បង្កើនចំនួនវាយតំលៃការខូចខាតដោយគ្រោះមហន្តរាយរបស់អ្នក
- កុំអោយនរណាម្នាក់ធ្វើការអោយអ្នក ដោយកក់លុយច្រើនជាមុន ។ ចេញជាមូលប្បទានប័ត្រ ឬ ប័ណ្ណឥណទាន ដើម្បីរក្សាកំណត់ត្រាទុក និង ចៀសវាងការចំណាយពីរដង ។

**ប្រសិនបើអ្នកគិតថាអ្នកជាជនរងគ្រោះដោយសារការបោកប្រាស់ ឬ សង្ស័យលើសកម្មភាពបោកប្រាស់ សូមរាយការណ៏មកកាន់ការិយាល័យអគ្គអធិការលូស៊ីអាណា តាមលេខ**

**1-800-351-4889.**

# ការត្រៀមខ្លួនសំរាប់គ្រាអាសន្ន

ភាពទំនងរបស់អ្នក និង គ្រួសាររបស់អ្នករួចជីវិតពីអគ្គីភ័យ គឺអាស្រ័យទៅលើការមានឧបករណ៍ផ្តល់សញ្ញាថាមានផ្សែង និង ផែនការរត់គេច និង ការរស់នៅក្នុងសហគមន៍ ជាមួយគ្នានឹងការិយាល័យអគ្គីភ័យ ដែលឆ្លងកាត់ការបណ្តុះបណ្តាលយ៉ាងល្អ ។




**ដូចគ្នានេះដែរ គឺពិតប្រាកដសំរាប់ការរស់រានមានជីវិតពីគ្រោះមហន្តរាយដទៃទៀត ។**

យើងត្រូវមានឧបករណ៍ និង ផែនការត្រៀមខ្លួនរួចជាស្រេច ដើម្បីរស់រានដោយខ្លួនឯង យ៉ាងហោចណាស់សំរាប់រយៈពេលមួយ មិនថាយើងនៅកន្លែងណា ពេលដែលមានគ្រោះមហន្តរាយកើតឡើង ។ ព័តិមានលំអិតបន្ថែមអំពីការត្រៀមខ្លួនគ្រាមានអាសន្នមានលើវ៉ិបសាយសំរាប់ការត្រៀមខ្លួន របស់ក្រសួងសន្តិសុខដែនដីសហរដ្ឋអាមេរិក (DHS) www.ready.gov ឬ នៅក្នុងសៀវភៅមគ្គុទេសក៏ត្រៀមខ្លួនសំរាប់គ្រាអាសន្ន ដែលបង្កើតឡើងដោយ DHS និង សម្ព័ន្ធម្ចាស់ផ្ទះ ។ សៀវភៅមគ្គុទេសក៏នេះ អាចបញ្ជាទិញបានដោយទូរស័ព្ទទៅលេខ **1-800-BE-READY** ។

## បង្កើតផែនការទំនាក់ទំនងគ្រួសារ



គ្រួសាររបស់អ្នកប្រហែលជាមិននៅជាមួយគ្នា នៅពេលមានគ្រោះមហន្តរាយ ដូច្នេះរៀបចំផែនការពីរបៀបដែលអ្នកនឹងទាក់ទងគ្នា និង ពិនិត្យឡើងវិញអំពីអ្វីដែល អ្នកនឹងធ្វើ នៅក្នុងស្ថានភាពផ្សេងៗ ។

**ពិចារណាលើផែនការ ដែលសមាជិកគ្រួសារនីមួយៗ អាចទូរស័ព្ទ ឬ អ៊ីមែលទៅកាន់មិត្តភ័ក្រ្ត ឬ សាច់ញ្ញាតិតែមួយ ពេលដែលមានគ្រាអាសន្នកើតឡើង ។**

វាប្រហែលជាងាយស្រួលជាង ក្នុងការហៅទូរស័ព្ទរយៈវែង ជាងហៅទូរស័ព្ទនៅក្នុងក្រុងតែមួយ ដូច្នេះ ការទំនាក់ទំនងគ្នានៅខាងក្រៅរដ្ឋ អាចមានលក្ខណៈល្អប្រសើរជាង ដើម្បីធ្វើការប្រាស្រ័យទាក់ទងគ្នារវាងសមាជិកគ្រួសារដែលបែកបាក់ ។ ធានាថាមនុស្សម្នាក់ៗ ដឹងពីលេខទូរស័ព្ទ ហើយ មានកាក់ ឬ កាតទូរស័ព្ទ ដើម្បីហៅទូរស័ព្ទ ទៅលេខទំនាក់ទំនងគ្រាអាសន្ន ។

អ្នកក៏ប្រហែលជាចង់សួរសំនួរអំពីផែនការគ្រាអាសន្ន នៅទីកន្លែង ដែលគ្រួសាររបស់អ្នកចំណាយពេលវេលាលើៈ កន្លែងធ្វើការ ទារកដ្ឋាន និង សាលារៀន ។ ប្រសិនបើពុំមានផែនការទេ ពិចារណាលើការងារស្ម័គ្រចិត្តដើម្បីបង្កើតផែនការមួយឡើង ។ និយាយទៅកាន់អ្នកជិតខាងរបស់អ្នក អំពីរបៀបដែលអ្នកអាចធ្វើការជាមួយគ្នា នៅពេលមានគ្រាអាសន្នកើតឡើង ។ អ្នកនឹងត្រៀមខ្លួនបានប្រសើរជាងមុន ដើម្បីជួបជុំគ្រួសារ និង អ្នកជាទីស្រលាញ់របស់អ្នកឡើងវិញ ប្រសិនបើអ្នកគិតជាមុន និង ទំនាក់ទំនងជាមួយអ្នកផ្សេងទៀតជាមុន ។

## ធានារ៉ាប់រងទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់អ្នក

ទំនាក់ទំនងភ្នាក់ងារ ឬ ក្រុមហ៊ុនធានារ៉ាប់រងរបស់អ្នក ដើម្បីពិនិត្យឡើងវិញ លើការធានារ៉ាប់រងរបស់អ្នកមកលើគោលនយោបាយទ្រព្យសម្បត្តិដែលមានស្រាប់ ដើម្បីពិនិត្យមើលថាតើទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់អ្នក ត្រូវបានធានារ៉ាប់រង ខណៈពេលដែលអ្នករស់នៅក្នុងជំរកបណ្តោះអាសន្នដែរឬទេ ។ ការធានារ៉ាប់រងទឹកជំនន់ តាមរយៈកម្មវិធីធានារ៉ាប់រងទឹកជំនន់ជាតិ (NFIP) នឹងមិនមានឡើយ ប្រសិនបើអ្នករស់នៅក្នុងរថយន្តសណ្តោង ។ ការធានារ៉ាប់រងរបស់ NFIP នៅក្នុងផ្ទះសាងសង់**អាច**មាន ប៉ុន្តែ ត្រូវរង់ចាំរយៈពេល 30 ថ្ងៃ ដើម្បីដាក់ធានារ៉ាប់រងអោយចូលជាធរមាន ។ សំរាប់ព័តិមានទូទៅ អ្នកអាចទំនាក់ទំនង **NFIP** តាមលេខ **1-800-427-4661** ។

## បង្កើតកញ្ចប់ផ្គត់ផ្គង់គ្រាអាសន្នសំរាប់គ្រួសាររបស់អ្នក



ទឹក ម្ហូបអាហារ និង ខ្យល់ស្អាត មានសារៈយ៉ាងខ្លាំងសំរាប់ការរស់រានមានជីវិត ។ កញ្ចប់ របស់មនុស្សម្នាក់ៗ ឬ គ្រួសារនីមួយៗ គួរសមស្រប ដើម្បីបំពេញតំរូវការរបស់ពួកគេ ដូចជា មានថ្នាំពេទ្យ និង ទឹកដោះគោសំរាប់ទារក ។ វាក៏គួររួមមានឯកសារសំខាន់ៗរបស់គ្រួសារផងដែរ ។ រក្សាឯកសារសំខាន់ៗរបស់គ្រួសារ ដូចជា គោលនយោបាយធានារ៉ាប់រង អត្តសញ្ញាណប័ណ្ណ និង របាយការណ៍ធនាគារ នៅក្នុងប្រដាប់ដាក់ដែលអាចយួរបាន និង ដែលមានជ្រាបទឹក ដូចជា កាបូបមានរូតជាដើម ។

ប្រភពៈ ក្រសួងសន្តិសុខដែនដីសហរដ្ឋអាមេរិក

**គ្រឿងផ្គត់ផ្គង់រួមមានៈ**

**ទឹក** - ទឹកមួយហ្គាឡុន សំរាប់មនុស្សម្នាក់ក្នុងមួយថ្ងៃ សំរាប់ការបរិភោគ និង អនាម័យ
**វិទ្យុប្រើថ្ម ពិល** និង **ថ្មបន្ថែម**
**កញ្ចប់សង្គ្រោះបឋម**
**កញ្ចែ** ផ្លុំដើម្បីផ្តល់សញ្ញាថាត្រូវការជំនួយ
**ម៉ាស់ធូលី** ឬ អាវយឺតូតុង ដើម្បីច្រោះខ្យល់
**កូនកន្សែងសើម** សំរាប់អនាម័យ
**ម៉ាឡេ ឬ ដង្កាប់** ដើម្បីបិទទឹកភ្លើង
**ផ្ទាំងប្លាស្ទិកស្តើងៗ** និង **បំពង់ទីប** ដើម្បីធ្វើជំរក
**ទឹកដោះគោកូនក្មេង** និង **កន្ទប** ប្រសិនបើអ្នកមានទារក
**ថង់សំរាម** និង **ចំណងប្លាស្ទិក** សំរាប់អនាម័យផ្ទាល់ខ្លួន